# ការមានភាពស៊ាំនៅក្នុងសហគមន៍

**ប្រសិនបើមានមនុស្សនៅខោនធី Los Angeles គ្រប់គ្រាន់ទទួលថ្នាំបង្ការជំងឺ COVID-19 យើងអាចទទួលបានការមានភាពស៊ាំនៅក្នុងសហគមន៍។ នេះមិនត្រឹមតែការពារអ្នកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការពារក្រុមគ្រួសារ មិត្តភក្តិ និងអ្នកជិតខាងទៀតផង!**



## តើការមានភាពស៊ាំនៅក្នុងសហគមន៍គឺជាអ្វី ហើយហេតុអ្វីបានជាវាសំខាន់ម្ល៉េះ?

ការមានភាពស៊ាំនៅក្នុងសហគមន៍ ដែលគេអាចស្គាល់បានដែរថាការមានភាពស៊ាំជាហ្វូង (herd immunity) គឺនៅពេលដែលមានមនុស្សគ្រប់គ្រាន់នៅក្នុងតំបន់មួយក្លាយទៅជាស៊ាំទៅនឹងជំងឺឆ្លងមួយដែលវាអាចធ្វើឱ្យការឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់កាន់តែពិបាក។ ដោយសារតែវិធីនេះ សហគមន៍ទាំងមូលត្រូវបានការពារ - ហើយមិនមែនត្រឹមតែសម្រាប់មនុស្សដែលស៊ាំនឹងជំងឺហើយប៉ុណ្ណោះទេ។ វាជារបៀបដែលយើងបញ្ឈប់ការរីករាលដាលនៃជំងឺដូចជាជំងឺខ្វិន និងកញ្ជ្រិល។ ការមានភាពស៊ាំនៅក្នុងសហគមន៍គឺមានសារៈសំខាន់ ព្រោះវាការពារមនុស្សដែលមិនអាចចាក់ថ្នាំបង្ការបាន ដូចជាទារក និងកុមារតូចៗ។ វាក៏ជួយដល់មនុស្សមួយចំនួនដែលមិនអាចទទួលយកថ្នាំបង្ការបានទាំងស្រុងផងដែរ ដូចជាអ្នកដែលមានប្រព័ន្ធភាពស៊ាំខ្សោយ។



## តើយើងអាចសម្រេចវាបានយ៉ាងដូចម្តេច?

ការមានភាពស៊ាំនៅក្នុងសហគមន៍កើតមានឡើងនៅពេលដែលមានមនុស្សគ្រប់គ្រាន់បានចាក់ថ្នាំបង្ការ និង/ឬនៅពេលដែលមានមនុស្សគ្រប់គ្រាន់បានជាសះស្បើយពីការឆ្លង ហើយបង្កើតការឆ្លើយតបនៃប្រព័ន្ធភាពស៊ាំ (ភាពស៊ាំធម្មជាតិ)។ ចំនួនភាគរយនៃប្រជាជនដែលត្រូវការឱ្យមានភាពស៊ាំដើម្បីឈានដល់ការមានភាពស៊ាំនៅក្នុងសហគមន៍ អាស្រ័យលើថាតើជំងឺនេះរាលដាលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ងាយស្រួលប៉ុណ្ណា។ ជាធម្មតាវាប្រហែលជា 70% ទៅ 90% នៃចំនួនប្រជាជន។



## សម្រាប់ជំងឺ COVID-19 យើងមិនអាចពឹងផ្អែកលើភាពស៊ាំធម្មជាតិបានទេ ពីព្រោះ៖

- មនុស្សជាច្រើនអាចឈឺ ឬស្លាប់ មុនពេលដែលឈានដល់ការមានភាពស៊ាំនៅក្នុងសហគមន៍។
- ការពន្យាពេលណាមួយអាចបង្កើនឱកាសឱ្យមេរោគ COVID-19 ប្រភេទថ្មីមានការរីករាលដាលយ៉ាងឆាប់រហ័ស និងចាប់ផ្តើមត្រួតត្រា។
- ភាពស៊ាំធម្មជាតិអាចមិនមានរយៈពេលយូរគ្រប់គ្រាន់ ឬខ្លាំងគ្រប់គ្រាន់ ហើយមនុស្សអាចមានការឆ្លងម្តងទៀត។



## ការចាក់ថ្នាំបង្ការគឺជាមធ្យោបាយលឿនបំផុតក្នុងការការពារខោនធី LA!

នៅពេលដែលមនុស្សមានគ្រប់គ្រាន់បានចាក់ថ្នាំបង្ការប្រឆាំងនឹងជំងឺ COVID-19 មេរោគមិនអាចឆ្លងរាលដាលពីមនុស្សម្នាក់ទៅមនុស្សម្នាក់បានយ៉ាងងាយទេ មានន័យថាសហគមន៍របស់យើងទាំងមូលមិនទំនងនឹងឆ្លងជំងឺ COVID-19 ទេ។ ប្រសិនបើមនុស្សម្នាក់ឈឺដោយចៃដន្យ វាក៏អាចមានហានិភ័យតិចតួចក្នុងការរីករាលដាលនៃជំងឺ COVID-19 ប្រសិនបើមិនមានមនុស្សច្រើនដែលអាចឆ្លងមេរោគបានទេ វាធ្វើឱ្យជំងឺនេះកម្រនឹងកើតមានបានណាស់។



## សូមធ្វើចំណែករបស់អ្នក - ទទួលចាក់ថ្នាំបង្ការឱ្យបានកាន់តែឆាប់កាន់តែល្អ!

- ការចាក់ថ្នាំបង្ការគឺជាវិធីដែលមានសុវត្ថិភាពក្នុងការដើម្បីបង្កើតប្រព័ន្ធការពារ ជាងការឆ្លងមេរោគ COVID-19។
- ថ្នាំបង្ការជំងឺ COVID-19 មានសុវត្ថិភាព និងមានប្រសិទ្ធភាព។
- ការចាក់ថ្នាំបង្ការនឹងជួយឱ្យអ្នក និងមនុស្សជាទីស្រឡាញ់របស់អ្នកមានសុវត្ថិភាពពីការឈឺ មិនបានធ្វើការងារ ចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬការស្លាប់បាន។

ចូលទៅកាន់គេហទំព័រ **www.VaccinateLACounty.com** សម្រាប់ព័ត៌មានបន្ថែម ឬទូរស័ព្ទទៅលេខ **833-540-0473** រវាងម៉ោង 8:00 ព្រឹកដល់ម៉ោង 8:30 យប់ បម្រើការ 7 ថ្ងៃក្នុងមួយសប្តាហ៍សម្រាប់ជំនួយផ្សេងៗក្នុងការធ្វើការណាត់ជួប។

County of Los Angeles Public Health